# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0136**

## សម្ភាសន៍ជាមួយឈ្មោះ កែវ ជឿន ភេទប្រុស អាយុ៦៣ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ កងចល័តនៅអាងត្រពាំងថ្ម
## ស្រុកកំណើតនៅភូមិទួលត្នោត ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល
## សព្វថ្ងៃរស់នៅភូមិប៉ោយក្បឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ហ៊ិន សុផានី
## ០០:៤៨:១៥
## ២៧ទំព័រ

ផានី : ថ្ងៃនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ។ ខ្ញុំឈ្មោះ ផានី មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយកន្លែងពួកខ្ញុំនឹង ចុះមកនេះស្រាវជ្រាវទាក់ទងពីសម័យខ្មែរក្រហម ។ ពួកខ្ញុំចុះមកនេះចង់សាក់សួរប្រវត្តិពូ ដែលពូបានឆ្លងកាត់ពូសម័យខ្មែរក្រហមរហូតមកដល់ឥឡូវតើ ពូបានឆ្លងកាត់ជួបប្រទះរឿងរ៉ាវអីខ្លះ ។ ហើយរឿងរ៉ាវទាំងអស់នេះ ពួកខ្ញុំសុំយកមកសរសេរជាអត្ថបទ ក៏ដូចជាសម្រាប់អ្នកសិក្សាស្រាវជ្រាវផ្សេងៗ យកមកប្រើប្រាស់ទុកឲ្យក្មេងៗជំនាន់ក្រោយបានដឹងបានរៀនបានសូត្រ ។ ជាដំបូងខ្ញុំសុំថតជាសម្លេងក៏ដូចជារូបថតបានទេ?

ជឿន : ចុះមានអី ។

ផានី : ចឹងពូមានឈ្មោះអីដែរ?

ជឿន : កែវ ជឿន ។

ផានី : ពូឆ្នាំនឹងអាយុប៉ុន្មានហើយ?

ជឿន : អាយុ៦៣ឆ្នាំ ។

ផានី : ពូមានស្រុកកំណើតនៅណា?

ជឿន : ស្រុកកំណើតនៅស្រុកអង្គស្នួល អឺ!ស្រុកភ្នំពេញ ។

ផានី : នៅភូមិឃុំអីដែរ?

ជឿន : បើនិយាយពីភូមិកំណើតខ្ញុំ ភូមិទួលត្នោត ឃុំពើក ស្រុកអង្គស្នួល ។

ផានី : ចឹងខេត្តកណ្តាល?

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ជឿន ៖ ខេត្តកណ្តាល ។

ធានី ៖ ចុះរាល់ថ្ងៃ ពូរស់នៅណា?

ជឿន ៖ ខ្ញុំរស់នៅភូមិប៉ោយក្បឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកពូឈ្មោះអីដែរ?

ជឿន ៖ ឪពុកខ្ញុំស្លាប់ហើយ ។

ធានី ៖ ចាំ! គាត់ឈ្មោះអី?

ជឿន ៖ ប៉ក់ កែវ ។

ធានី ៖ គាត់ស្លាប់ពេលណាដែរ?

ជឿន ៖ ស្លាប់តាំងសម័យលន់ នល់ តាំងពីឆ្នាំ៧១ ។

ធានី ៖ ដោយសារអីដែរ?

ជឿន ៖ ដោយសារ ជម្ងឺ ។

ធានី ៖ ចុះម្តាយឈ្មោះអី?

ជឿន ៖ ម្តាយ ឃ្មោត ទី ។

ធានី ៖ គាត់នៅរស់?

ជឿន ៖ ស្លាប់ដែរ ពីសម័យប៉ុលពតនោះ ។

ធានី ៖ ពេលណា?

ជឿន ៖ ៧៩ អឺ! ៧៧នៅឃុំទឹកជោរ ។

ធានី ៖ ដោយសារអីដែរ?

ជឿន ៖ ដោយសារអត់បាយនឹង ។

ធានី ៖ ចុះពូមានបងប្អូនប៉ុន្មាននាក់?

ជឿន ៖ បងប្អូនខ្ញុំ៤នាក់ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ជឿន ៖ ស្រីតែ១ ប្រុស៣ ។

ធានី ៖ គាត់នៅរស់ទេ?

ជឿន ៖ អាប្រុស១នោះ ចល័តសម័យប៉ុលពតនោះបាត់ខ្លួន ។

ធានី ៖ បាត់ខ្លួន?

ជឿន ៖ បាត់ខ្លួន មិនដឹងស្លាប់ ឬរស់ ចល័តនៅសាលាក្រហម បាត់ខ្លួន ។

ធានី ៖ តែ១នឹងទេ?

ជឿន ៖ អាមួយទៀតនៅស្រុកនោះទេ ហើយស្រី១ទៀតស្លាប់ដែរ ។

ធានី ៖ ស្លាប់ដោយសារអី?

ជឿន ៖ ស្លាប់នៅឃុំទឹកជោរនឹង ។

ធានី ៖ ដោយសារអីដែរ?

ជឿន ៖ រឿងអត់បាយជាមួយគ្នា ធ្វើការបាក់កម្លាំង ។

ធានី ៖ បាត់បងប្អូនស្រី១ ប្រុស១ ។

ជឿន ៖ បាទ! ស្លាប់អស់២ អាមួយនៅភ្នំពេញ អឺ!នៅស្រុកធ្វើការ ។

ធានី ៖ មួយទៀតនៅនេះ?

ជឿន ៖ បាទ! មួយទៀតនៅនេះ នៅតែ២នាក់ទេ ។

ធានី ៖ ពូរៀបគ្រួសារឆ្នាំប៉ុន្មាន?

ជឿន ៖ ឆ្នាំ៨០ ។

ធានី ៖ ១៩៨០?

ជឿន ៖ បាទ!

ធានី ៖ គ្រួសារពូឈ្មោះអីគេ?

ជឿន ៖ នេះ ជួន រ៉ន ។

ធានី ៖ មានកូនប៉ុន្មាននាក់?

ជឿន ៖ កូនតែ៣ទេ ។

ធានី ៖ ស្រី?

ជឿន ៖ ស្រី២ ប្រុស១ ។

ធានី ៖ ចុះពូរៀនសូត្របានត្រឹមថ្នាក់ទីប៉ុន្មាន?

ជឿន ៖ ខ្ញុំរៀនបានល្មម ម៉ាចេះមើល ចេះអានធម្មតា ។

ធានី ៖ រៀនថ្នាក់ទីប៉ុន្មានកាលសម័យនឹង?

ជឿន ៖ សម័យនឹងថ្នាក់ទីបញ្ចប់ប៉ុននឹង ។

ធានី ៖ ទី១?

ជឿន ៖ មធ្យមសិក្សាប័ត្រភាគII គ្រាន់និយាយប្រាប់ឲ្យត្រង់បាក់ឌុប ។

ធានី ៖ ចឹងពូចប់បាក់ឌុប? ចឹងបានសញ្ញាប័ត្របាក់ឌុប គេហៅចឹង?

ជឿន ៖ បាទ!

ធានី ៖ ហើយបន្ទាប់មកទៀត ពូធ្វើអីទៅ?

ជឿន ៖ គ្មានធ្វើអីទេ ។

ធានី ៖ ពេលចប់បាក់ឌុប?

ជឿន ៖ បាទ!

ធានី ៖ ចុះម៉េចបានពូទៅនៅភ្នំពេញ?

ជឿន ៖ នៅភ្នំពេញបើរៀននៅភ្នំពេញនៅវត្ត ដល់ពេលសម័យដែលចេញ ពេលដែលជម្លៀសចេញ មកៗផ្ទះដល់ពេលចុងក្រោយមកទៀត បានគេជម្លៀសម្ដាយខ្ញុំទាំងបងប្អូនខ្ញុំចេញពី សំរោងទង ។ ត្រឡប់ពីសំរោងទងមកទៀត បានគេបញ្ជូនមកបាត់ដំបង នេះ ។ បាត់ដំបង នេះ ធ្លាក់មកដល់ឃុំទឹកជោរនេះ បានគេឲ្យស្នាក់នៅឃុំប៉ោយចារ ស្នាច់នឹង ។ បន្ទាប់មក ទៀតបានគេដូចខ្ញុំយុវជននឹងបំបែកចេញ ។

ធានី ៖ ចឹងបានដកភូមិប៉ោយចារ បានគេបំបែក?

ជឿន ៖ បាទ! បំបែកទៅម្ដាយខ្ញុំ ប្អូនខ្ញុំបែកគ្នាអស់ហើយ ម្ដាយខ្ញុំគាត់នៅធ្វើការតាមភូមិនឹងទៅឯប្អូនខ្ញុំនៅតាមចល័តទាំងអស់គ្នា ។ ដល់ពេលចុងក្រោយទៀត អត់ដែលបានទៅផ្ទះទេ រហូត រែកតែដី មើលតែគោ ភ្ជួរតែស្រែ កាប់តែព្រៃនឹង ដាំដំឡូង ដាំអីនឹង អត់ដែលបានជួបបងប្អូនទេ ។ ពេលណាសុំមកជួបបងប្អូនម្ដងៗគេអត់ឲ្យមកទេ គេចោទប្រកាន់យើងថាខ្មាំង យើងនៅគ្រួសារនិយមបងប្អូន និយមបក្សពួក គេនិយាយរឿងនឹង ។ ដល់ពេលនេះយើងម៉េចនឹងហ៊ានមក បើគេនិយាយរបៀបនឹងក៏ចប់ទៅ ។ ហើយដល់ពេលក្រោយមក ទៀត អានឹងនិយាយពីបងប្អូនឈឺ ម្ដាយឈឺ សុំមកសួរអីអត់បានទេ គេថាពេទ្យគេមាន ហើយមិនបាច់អ្នកឯងមកទេ អ្នកឯងមិនមែនពេទ្យទេ អ្នកឯងធ្វើការបម្រើអង្គការទៅ ហ្នឹងហើយអានឹងមួយទៅ ។ ម្ដាយខ្ញុំស្លាប់ ។ ដល់ប្អូនស្រីមួយទៀត ឈឺ ប្រើ ដឹងថាប្អូន ស្រីឈឺហើយ សុំមកសួរសុខទុក្ខមើល គេអត់ឲ្យជួបទៀត នៅកន្លែងនេះ អាពេទ្យខ្មែរ ក្រហម នៅឃុំទឹកជោរ ។ ប្អូនស្រីខ្ញុំស្លាប់នៅនឹងឃុំទឹកជោរ អត់មានដឹង អត់ឃើញខ្មោច គ្មានឃើញឆ្អឹងអីទេ គេមិនប្រាប់ គេថាពិបាកគិតគេដាំដំឡូងដាំអីអស់ ។

ធានី ៖ គេនិយាយចឹង?

ជឿន ៖ បាទ! គេថាដាក់ចំការ គេកាប់ព្រៃដំដំឡូងដាំអី មិនបាច់រកឆ្អឹងរកអីទៀតទេ អ្នកស្រុកដែលរាប់អានគ្នា ដែលសួរទៅគេថាបងប្អូនមិត្តឯងនោះប្អូនមិត្តឯងនោះ ម្តាយមិត្តឯងនោះ គេដាំដំឡូងអស់ហើយ ធ្វើចំការដាំដំឡូង។ ខ្ញុំនៅតែប្អូនខ្ញុំ អាប្រុសមួយដែលនៅភ្នំពេញដែល ធ្វើសាស្ត្រាចារ្យនឹង ហើយនឹងខ្ញុំមួយប៉ុននឹងឯងដែលនៅរស់។ ហើយអាមួយទៀតចល័ត នៅសាលាក្រហម ក៏បាត់ខ្លួន។ ទៅមិនបាត់ណា បើសម័យវៀតណាមចូលមកវិញអត់ មានជួបគ្នាចប់ នឹងហើយរហូត៣០ឆ្នាំហើយ អត់មានពុសូរស្អីសោះ បែកថាចប់។ សន្មត ថាចប់។

ធានី ៖ រងចាំដែរ?

ជឿន ៖ រងចាំដែរ នៅសួររកដែល ដល់ពេលនេះទៅវាសូន្យ បាត់ដំណឹងឈឹង អានឹងហើយវិនាសកម្មអស់។ យើងនិយាយថាវិនាសកម្មចប់ហើយ។

ធានី ៖ ចឹងពូគិតថា ប្អូនពូស្លាប់ហើយ?

ជឿន ៖ អានឹងសន្មតថាស្លាប់ ព្រោះ៣០ឆ្នាំហើយ អ្នកណាក៏មិនអាចថានៅរស់បានដែរ។ ដែលសួរ អ្នកខ្លះដែលគេរត់រួច ថាងាប់ហើយ ព្រោះវាចាប់។ ដល់ពេលបែកគ្នាពួកកងទ័ពវាចាប់។ តែកងទ័ពចាប់ហើយ វាមិនដែលរស់ទេ វាចប់រឿង សន្មតថា ចប់។

ធានី ៖ បែក៧៩?

ជឿន ៖ មុន៧៩តិច ថាដើម មុនវៀតណាមប្រហែល៥-៦ខែប៉ុននោះឯង។

ធានី ៖ ចុង៧៨?

ជឿន ៖ នោះ ប៉ុននោះឯង ចប់ទៅបាត់ទៅ អានឹងរឿងខ្ញុំ។

ធានី ៖ ចឹងពូពូនិយាយថា ប្អូនពូធ្វើសាស្ត្រាចារ្យ ធ្វើឥឡូវ ឬធ្វើមុននឹង?

ជឿន ៖ សព្វថ្ងៃ។ ប្អូនតូច គេទៅនៅជាមួយមាមីងនៅនោះទៅ គេរៀនសូត្រ គេប្រឡងគ្រូ បានត។ដល់សព្វថ្ងៃនឹង។ មកលេងមកអីម្តងដែរ តែខ្ញុំក៏ធ្លាប់ទៅលេង៣-៤ដងដែរ ដល់ក្រោយទៀតខ្ញុំឈប់ទៅ អាខ្សែងការងាររច្រើនដង ហើយណាមួយថវិកាយើងវាតិចតួចណាស់ កន្លែងបញ្ជូនឲ្យអ្នករៀននៅភ្នំពេញ២នាក់នោះ។ អាកូន២នាក់រៀននៅភ្នំពេញ។

ធានី ៖ ចឹងចង់សួរបកក្រោយតិច ដូចថាដំបូងពូមកនៅរៀននៅភ្នំពេញដើម្បីរៀន តែរៀនចប់បានសញ្ញាប័ត្រថ្នាក់ទី១២?

ជឿន ៖ ចប់ហើយ បាន។

ធានី ៖ ហើយចឹងពូធ្វើអីទៀតទៅ?

ជឿន ៖ អត់បានធ្វើអីទេ ។

ធានី ៖ ដល់ពេល៧៥នឹង គឺបាន?

ជឿន ៖ ចប់រឿង គ្រាន់ថាយើងជ្រើសរើសការងារអត់ទាន់បានថា យើងត្រូវធ្វើអីដែរ ចប់រឿងបណ្តោយ ។

ធានី ៖ ចឹងយើងកំពុងរកការងារ?

ជឿន ៖ ហ្នឹង តើយើងត្រូវធ្វើយ៉ាងម៉េច អីយ៉ាងម៉េចទៀត ។

ធានី ៖ ហើយពេលនឹង ពូមានអារម្មណ៍យ៉ាងម៉េច ដល់ពេលខ្មែរក្រហមទ័ពអីគាត់ចូលមកដល់ ៧៥ ដល់កន្លែងគេនៅភ្នំពេញអីចឹង?

ជឿន ៖ មានអារម្មណ៍ដែរ មានអារម្មណ៍ថាដូចថាជីវិតយើងចប់ត្រឹមប៉ុននេះ ។

ធានី ៖ គិតចឹង?

ជឿន ៖ ព្រោះធម្មតារៀងយើងរៀនសូត្រ ក៏ដឹងដែរ ដឹងថាខ្មែរក្រហមវាយ៉ាងម៉េច គំនិតជាស៊ីសស្រេចហើយ ។

ធានី ៖ ចឹងពូគិតពីដំបូង?

ជឿន ៖ ខ្ញុំជឿថាខ្មែរក្រហមចឹង កុំអីខ្ញុំមិនអាចរស់បាន ព្រោះខ្ញុំយល់ដឹងថា រឿងអានឹងវាត្រូវតែធ្វើរបៀបគំនិតមួយគំនិតផ្តាច់ការអំណាចផ្តាច់ការខ្លួនវា ។
វាអត់មានគំនិតណាមួយដែលកាន់ ល្អដូចយើង មានកាន់សាសនាអីត្រឹមត្រូវទេ ព្រោះវាដឹងស្រាប់ហើយតើ ត្មិលឥសាសនា វាចូលអាម៉ាក់នោះហើយណា ។

ធានី ៖ តែម៉េចពូដឹង ព្រោះអីធម្មតា?

ជឿន ៖ ធម្មតាកូនសិស្សរៀន វាមិនដុតទេ ។

ធានី ៖ ដូចថាមានការឃោសនា?

ជឿន ៖ មិនមានការឃោសនា ការសិក្សារៀនសូត្រ អក្សរសាស្ត្រយើង ដែលតែងតែមានអត់ដែលអត់ទេ កាលណាយើងស្តាប់សូរ ធម្មតាពីសង្គមមួយទៅសង្គមមួយ យើងទៅរៀនសូត្រអាចដឹង ។ យើងដឹងស្រាប់ហើយតើ អារឿង វាមិនមែនអត់ទេ ព្រោះកាលមុនមិញដែលយើងដឹងថា តើខ្មែរក្រហមវាស្រួលប៉ុនណា ខ្ញុំអត់ជឿថាខ្មែរក្រហមស្រួលទេ ខ្ញុំតាំងពីដើម ឲ្យតែអាក្រហមឈ្នះ គឺថាយើងវលាយទាំងអស់គ្នា គ្មានសល់អី ។

ធានី ៖ ពូគិតចឹងហើយ?

ជឿន ៖ បាទ!

ធានី ៖ ដូចថាមុនពេលរៀនឆ្នាំ៧០ អីចឹង នៅសាលារៀននៅភ្នំពេញចឹង មានការឃោសនាពីអ្នកនេះពីអ្នកនោះ ពូដែលធ្លាប់ឮរឿងនឹងទេ?

ជឿន ៖ ទេ! រឿងនឹងអត់ដែលបះទេ ខ្ញុំមិនដែលបះទេ តែចិត្តគំនិតខ្ញុំគឺថា ឮតែក្រហមហើយដូចមិនសូវស្រួលចិត្ត ខ្ញុំជឿថាចឹង ព្រោះក្រហមនឹង ។

ធានី ៖ ចុះពូឮក្រហមនឹងពីអង្កាល់?

ជឿន ៖ ឮក្រហមតាំងពីឆ្នាំជាប់ឌីប្លូមហើយ ក៏ឮនិយាយដែរ តែក្រហមនឹងវានិយាយៗ វាមិនទាន់ឃើញច្បាស់ណាស់ ។

ធានី ៖ ឆ្នាំប៉ុន្មានដែរកាលនឹង ជាប់ឌីប្លូម?

ជឿន ៖ ជាប់ឌីប្លូមឆ្នាំ៦៧ ។

ធានី ៖ ពូជាប់បាក់ឌុបឆ្នាំប៉ុន្មាន?

ជឿន ៖ ចុងឆ្នាំ ជិតចប់ហើយ ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ជឿន ៖ ឆ្នាំ៧៣ ៧៤ដែរនឹង ។

ធានី ៖ ព្រោះពូជាប់ឌីប្លូម?

ជឿន ៖ ចាំមើល៣ឆ្នាំកន្លងមកទៀត ខ្ញុំរៀនដល់ពេលជាប់ហើយ ខ្ញុំឈប់សិន ព្រោះជីវភាពគ្រួសារខ្ញុំនៅឱន់ខ្សោយ ឪពុកខ្ញុំស្លាប់ទៅ យួនវៃអត់ថវិការៀនសូត្រត្រូវស្បៀយ ត្រូវសម្រាកការរៀនសូត្រ ។ អាកន្លែងត្រង់នឹងហើយ ដែលយើងត្រូវសម្រាកការសិក្សា ។

ធានី ៖ ហើយយើងមកធ្វើស្រែចំការ?

ជឿន ៖ មកជួយម្តាយខ្ញុំ ។ ដល់នេះឡប់ទៅវិញចង់រករៀនសូត្រតទៅទៀត ចប់ទៅ ។

ធានី ៖ មានបញ្ហា?

ជឿន ៖ មានបញ្ហារឿងជីវភាពគ្រួសារ ។

ធានី ៖ ចឹងពូឈប់រៀនតាំងឆ្នាំ៧៤?

ជឿន ៖ បាទ! ៧៤ ។

ធានី ៖ ៧៤ហើយពូអត់បាននៅភ្នំពេញ យើងទៅនៅអង្គស្នួល?

ជឿន ៖ នៅស្រុក អង្គស្នួលទៅបានម្តងៗទេ មិនបានទៅជាប់ទេ ព្រោះកាលនោះវាផ្តាច់ផ្លូវ ។

ធានី ៖ ចឹងពូត្រូវទៅនៅទីក្រុងភ្នំពេញដែរ?

ជឿន ៖ បាទ! នៅនឹងដែរ នៅជំរំពោធិ៍ចិនតុង ។

ធានី ៖ ហេតុអីបានពូទៅនៅជំរំពោធិ៍ចិនតុង?

ជឿន ៖ ព្រោះគេដាក់ជនភៀសខ្លួន គេដាក់ឲ្យនៅក្រៅសិន ។

ធានី ៖ ចឹងគេចាត់ទុកពូ ហើយនឹងកូនសិស្សផ្សេងៗ នៅក្នុងនឹង?

ជឿន ៖ អារឿងកូនសិស្ស អ្នករៀនចេះរៀន តែរឿងម្ដាយខ្ញុំនៅរស់ក្នុងជំរំជនភៀសខ្លួននឹងតើ ។

ធានី ៖ ម៉េចចឹងពូ?

ជឿន ៖ ចុះជីវភាពយើងខ្សោយ មិនអាចយើងនៅក្រៅកើតទេ ដល់ហើយត្រូវនៅតាមជំរំនេះដើម្បីឲ្យ ។

ធានី ៖ ដោយសារនៅចន្លោះ៧០ ដល់៧៥នឹង វាមានសង្គ្រាមរវាងខ្មែរក្រហមនិងយោធាលន់ នល់អីចឹង?

ជឿន ៖ បាទ!

ធានី ៖ ចឹងពូទៅនៅខាងលន់ នល់ រត់មកចឹង ឬមួយក៏ចឹង យ៉ាងម៉េច?

ជឿន ៖ ហ៊ឺ! លន់ នល់រត់ម៉េច បើនៅកន្លែងតំបន់ខ្ញុំនឹង ប្រទាញប្រទុងគ្នា វាវៃទម្លាក់គ្រាប់បែកចុះឡើងទៅ ខ្មែរក្រហមវាបាញ់ឆេះផ្ទះឆេះអីអស់ទៅ ប្រជាជនទាំងអស់នឹងប្រមូលផ្ដុំគ្នារត់ មកនៅភ្នំពេញ ។ ខ្លះក៏នៅពោធិ៍ចិនតុង ខ្លះក៏នៅជំពូវ័ន្ត ខ្លះក៏នៅ?

ធានី ៖ អានឹងគេមានជំរំរបស់គេ?

ជឿន ៖ បាទ! ហៅតួសំពៅ ។

ធានី ៖ បានន័យថាពូទៅនៅជំរំនឹងបណ្ដោះអាសន្ន ដើម្បីការពារខ្លួន?

ជឿន ៖ បណ្ដោះអាសន្ន ការពារខ្លួនដល់ពេលនឹង ចប់ត្រឹមជំរំនឹង ដល់ពេលចុងក្រោយ ដល់ពេលខ្មែរក្រហមចូលបាន ចប់ ។

ធានី ៖ ពេលនឹង អាចពូជួយរៀបរាប់ទិដ្ឋភាពនៅពេលខ្មែរ ពេលលន់ នល់ចាញ់ទៅ តើខ្មែរក្រហមចូលមកគេធ្វើយ៉ាងម៉េចខ្លះ ឃើញអីខ្លះចឹង?

ជឿន ៖ អូ! រឿងខ្មែរក្រហមចូលមក អត់មានរឿងអីអាក្រក់ រឿងអីល្អទេ គ្មានរឿងអីល្អទេ សុំទោស គេសុទ្ធអាខ្មាំងយួន អាខ្មាំងអីទាំងអស់ វាដេររួចស្រេច ។

ធានី ៖ ដើរតាម?

ជឿន ៖ ដើរតាមផ្លូវឃើញបាញ់ចោលឲ្យប្រៀបនឹង គ្មានរឿងអី ។

ធានី ៖ តែពេលខ្មែរក្រហម មកដល់ពូឃើញយ៉ាងម៉េចខ្លះ ឃើញទាហានអស់នឹងធ្វើយ៉ាងម៉េចខ្លះ ឬក៏គេនិយាយថាយ៉ាងម៉េចខ្លះបានដឹងថា លន់ នល់ចាញ់?

ជឿន ៖ ទេ! រឿងទាហាននឹងអត់មាននិយាយអីទេ គ្រាន់ទម្លាក់អាវុធៗ ទៅវាឡើងស្រែកៗ ។

ធានី ៖ ស្រែកថាម៉េច?

ជឿន ៖ វាស្រែកថាវាឈ្នះចឹង អាពួកខ្មែរក្រហមនឹងវារត់ពេញភ្នំពេញ ជិះម៉ូតូជិះឡាន..... ហើយទាហានដាក់អាវុធ ស្រាតខោអាវចោលទាំងអស់ ។ អានឹងខ្ញុំឃើញនឹងភ្នែក ។ អ្នកឯងទទឹងអ្នកឯងទៅលិច ចំទៅលិច តែថយមកក្រោយៗបាញ់ចោលដែរ ប្រជាជនក៏ដោយ អ្នកណាក៏ដោយ ឲ្យតែអ្នកឯងគេឲ្យទៅលិចទៅៗ ។

ធានី ៖ បន្ទាប់មកទៀតគេធ្វើម៉េចទៀត ពេលដែលលន់ នល់ ចាញ់ហើយ ទាហានអស់នឹងធ្វើយ៉ាង ម៉េច ឬក៏ខ្មែរក្រហមធ្វើយ៉ាងម៉េច?

ជឿន ៖ រឿងប្រជាជននៅភ្នំពេញជម្លៀសចេញអស់ អត់មានឲ្យនៅ ។

ធានី ៖ គេជម្លៀសចេញទៅណាវិញ?

ជឿន ៖ អ្នកណាឯងបែបមុខទៅណា ផ្លូវជាតិលេខ១ អ្នកឯងទៅផ្លូវជាតិលេខ១កុំបែបមកវិញ ។ អត់មានរឿងបែបគ្រួសារមកជួបវិញទេ បើថាពេលនឹងគឺថាអ្នកឯងត្រូវស្លាប់ វាបាញ់ ។

ធានី ៖ ខទាហរណ៍ថា ផ្ទះគាត់នៅផ្លូវជាតិលេខ៤ចឹង តែគាត់ស្រុកកំណើតនៅជាតិលេខ១ ក៏អត់ឲ្យមកដែរ?

ជឿន ៖ អត់ឲ្យមកទេ បើនាងឯងបើក ខបមាថានាងឯងបើកបែរមុខទៅផ្លូវជាតិលេខ៤ដើរទៅតាមផ្លូវជាតិលេខ៤ គិតថាខ្ញុំរកគ្រួសារខ្ញុំនៅពោធិ៍ចិនតុង ខបមានាងឯងដើរដល់ដំពូវន្ត នាងឯងមកដល់ត្រង់នេះវិញ គឺនាងឯងងាកក្បាលចេញពីត្រង់នឹងអត់ផុតទេ ។

ធានី ៖ ចុះពូមានបាត់គ្រួសារអីទេ?

ជឿន ៖ ពេលនឹងខ្ញុំអត់ទាន់មានបាត់គ្រួសារទេ គ្រួសារខ្ញុំនៅ ។

ធានី ៖ ចង់និយាយថាឪពុកម្ដាយ?

ជឿន ៖ ឪពុកម្ដាយខ្ញុំនៅស្រុក អត់ដែលជុំគ្នាទេ ទៅមកជុំគ្នា ។

ធានី ៖ ចឹងយើងដើរជុំគ្នា អត់មានបែកទេ?

ជឿន ៖ ជុំគ្នា អត់មានបែកទេ បើសិនណាបែក នាងឯងថយក្រោយទៅរកបង ឬបងប្អូននាងឯងត្រូវស្លាប់ អ្នករក ។

ធានី ៖ ពូបានឃើញផ្ទាល់ភ្នែក?

ជឿន ៖ ឃើញនឹងភ្នែក បាញ់ ។

ធានី ៖ ស្គាល់ឈ្មោះគាត់?

ជឿន ៖ អ្នកណាគេ បាញ់ ។

ធានី ៖ ហ្នឹងហើយ?

ជឿន ៖ អូ! អត់ស្គាល់ទេ ។

ធានី ៖ អ្នកដែលដូចថាគាត់វេចាំបងប្អូនសាច់ញាតិគាត់មកបន្ត?

ជឿន ៖ អារឿងនឹងមកចំរុះចុះឈ្មោះ ចុះជួបមិនដឹងមកពីខេត្តណា ។

ធានី ៖ ច្រើនទេ?

ជឿន ៖ អូ! បើនាងឯងកើតមិនទាន់ បើខ្ញុំកើតទាន់ដូចទៅមើលបុណ្យកឋិនចឹង វាពេញផ្លូវជាតិទាំងអស់នឹង ។

ធានី ៖ ចុះគេជម្លៀសទៅណា?

ជឿន ៖ ជម្លៀសទៅណា នាងឯងដើរតាមផ្លូវជាតិមកលិចចេះមកលិចទៅ អាអ្នកដើរផ្លូវជាតិលេខ១ ទៅណាតាកែវ កំពតទៅៗស្រេចតាមលក្ខណៈ ។

ធានី ៖ ចុះពូទៅណា?

ជឿន ៖ ខ្ញុំមកផ្ទះខ្ញុំ ស្រុកអង្គស្នួល ខ្ញុំឡប់មកស្រុក ។

ធានី ៖ ចឹងបានន័យថាអ្នកណាមកស្រុកណា អាចត្រឡប់ទៅស្រុកនឹងបាន?

ជឿន ៖ អានឹងទី១បើយើងនិយាយចឹង យើងទៅតែម្តងបាន គិចថាទៅដល់ផ្លូវជាតិលេខ១ សុំឡប់មកផ្លូវជាតិលេខ៤វិញ ដឹងថាងាប់ហើយ អត់មានបានទេ ។ វានិយាយ វាភ្ជង់ហើយស្រេច អត់មានបែរទេ ថាបែរមានតែងាប់ ។ និយាយឥឡូវបើចង់ឲ្យនាងឯងចេញ ថាឥឡូវយើងនៅជំរំនេះ យើងនៅកន្លែងគេសម្រេចហើយ ថាត្រង់នេះម៉ោង១ឲ្យចេញ គឺនាងឯងត្រូវចេញ បើនាងឯងមិនចេញ នាងឯងត្រូវ ។

ធានី ៖ ចុះពូមុនពេលជម្លៀសចឹង គេមានប្រាប់មុន២-៣ថ្ងៃឲ្យយើងរៀបអីវ៉ាន់អី?

ជឿន ៖ អត់មានប្រាប់ទេ ឥឡូវនាងឯងដើរមកសួរចេញៗម៉ោងប៉ុននឹងចេញឲ្យអស់ អានឹងដែលថា វាសង្កត់សង្កិន វាខ្លាំង ដូចខ្ញុំថា ។

ធានី ៖ ចឹងពូទៅអត់មានយកអីវ៉ាន់?

ជឿន ៖ អត់មានអីទេ មានតែខ្លួនតែប៉ុននឹង ។

ធានី ៖ ហើយទៅដល់ស្រុក?

ជឿន ៖ ទៅដល់ស្រុក អ្នកស្រុកគេឲ្យស៊ីឲ្យអី ។

ធានី ៖ ចុះហេតុអីបានពូត្រូវជម្លៀសបន្តជិតមកដល់ព្រះនេត្រព្រះ?

ជឿន ៖ ដល់នេះទៅគេរក១៧មេសា នៅក្នុងនោះវាមានអាអ្នកចាស់ អ្នកថ្មីដូចគ្នា ។ អាគេនៅក្នុងរំដោះនោះ គេនិយាយពាក្យម៉ាមាត់ក្នុងរំដោះ អ្នកឯងរំដោះគឺនៅចាំភូមិ ។ ហើយយើងអ្នក ថ្មីនេះ គឺយើងអត់ឲ្យនៅទេ យើងទៅលុតដី ។ ពាក្យថាលុតដីគេបញ្ជូនយើងឡើងឡានមក នៅបាត់ដំបង ពោធិ៍សាត់ តាមទិសដៅរបស់គេ ។

ធានី ៖ ចឹងពូមកនឹង ពូជិះឡានមកទេ?

ជឿន ៖ ជិះឡានៗ គេដឹកយកមកទម្លាក់ចោលភ្នំត្រយោងនេះ អាផ្លូវទៅ ថាភ្នំលាភនេះឯង ។ ផ្លូវទៅ នឹងគេបែងចែកទៅ អាណាទៅខាងណាទៅ ស្រេចគេបែងចែង ស្រេចទិសទៅ ។

ធានី ៖ ចុះកាលនឹងពូគេបែងចែកទៅណា?

ជឿន ៖ ខ្ញុំគេបែងចែកមកនៅ ឃុំប៉ោយចារ ភូមិប៉ោយចារ១ មកដល់ព្រឹកឡើងគេដេញឲ្យឯងទៅចល័តអស់ ។

ធានី ៖ ពូស្គាល់ឈ្មោះពួកគាត់ទេ ដែលចាត់ចែងឲ្យពូមកដល់ភូមិធ្វើអីៗ?

ជឿន ៖ អូ! ងាប់អស់ហើយ ពួកអានឹង ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ?

ជឿន ៖ ហ៊ឺ! មិនស្គាល់គេទេ ថ្មីៗ បើយើងមិនដឹងឈ្មោះអីៗ យើងមិនបាននៅផ្ទះ ព្រឹកឡើងដឹងប្រ៉ាវៗ ខ្ញុំអត់ដែលបានចូលភូមិទេ ខ្ញុំប្រាប់តាំងពីថ្ងៃទី១ចូលបានម៉ាភ្លែតទៅបាត់ ។

ធានី ៖ ចុះឪពុកម្ដាយពូនៅដាច់ដោយឡែកពីពូទៅ?

ជឿន ៖ ម្ដាយខ្ញុំនៅដោយឡែកពីខ្ញុំ ទៅប្អូនស្រីខ្ញុំទៅតាមចល័តទៅ អាប្អូនប្រុសខ្ញុំទៅតាមចល័តកុមារទៅ ។

ធានី ៖ ចឹងអត់ដែលបានជួបគ្នាទេ?

ជឿន ៖ គ្មានជួបគ្នាទេ ជួបព្យុថាស្លាប់ៗ វាចប់រឿងថាស្លាប់ អត់ឲ្យនៅជាមួយគ្នា ។

ធានី ៖ ចឹងដូចថាពេលនឹងពូគិតយ៉ាងម៉េចទៀតទៅ ដូចថាពូបានរៀន បានដឹងចឹងឃើញភាពចឹង?

ជឿន ៖ ដល់ពេលដែលយើងឃើញចឹង យើងថាអស់ទឹកចិត្តខ្លួនឯង ដឹងពេលណានឹងបានជួបក្រុមគ្រួសារ ពេលណាដើម្បីឲ្យមានសេរីភាពទៅទៀតដូចអត់មានពេលជួបប្រទះទេ អស់ទឹកចិត្តខ្លួនឯង ដឹងពេលណានឹងបានជួបក្រុមគ្រួសារ ពេលណាដើម្បីឲ្យមានសេរីភាពទៅទៀត វាអត់មានពេលជួបប្រទះទេ ។ បើធ្វើរបៀបនឹងទៅ ដូចងាប់ដាច់ពូជ ។ ខ្ញុំយល់ថាដាច់ពូជដល់ពេលចុងក្រោយ ដាច់ពូជខ្ញុំមែន ។

ធានី ៖ ចង់និយាយថាគេមួងគេឲ្យពូទៅធ្វើកងចល័តនឹង ទៅធ្វើអីខ្លះ?

ជឿន ៖ កងចល័តនឹង គេឲ្យ ។

ធានី ៖ ពូធ្វើយ៉ាងម៉េចដើម្បីថែរក្សាជីវិតមកដល់រាល់ថ្ងៃអីចឹង ការងារវាមានច្រើន?

ជឿន ៖ ស្រុកនៅចល័តនឹង ទី១គេឲ្យយើងកាប់ចំការ យើងធ្វើតាមធម្មតាទៅ គេឲ្យធ្វើម៉េចធ្វើតាមគេទៅ យើងអត់មានដូចថារឿងអីត្រូវប្រកែកទេ ។ អ្វីៗដែលយើងដឹងថាប្រកែក ដឹងថាស្លាប់ដែរ ឲ្យតែយើងជំទាស់ យើងខ្វាស់នឹងចលនាគេ ព្រោះគេនិយាយមុនស្រេចហើយ ។

ធានី ៖ គេនិយាយ អ្នកណាគេនិយាយ?

ជឿន ៖ ឈ្លបគេៗហើយថា មិត្តឯងប្រឆាំង គឺអ្នកឯងត្រូវតែខ្វាំង គេនិយាយចឹងម៉ាត់ទៅបាត់ទៅ បើអ្នកក្រោយទៀតចេះប្រើៗ រកអ្នកណាមួយប្រាកដថាមេយើងប្រាកដ ។

ធានី ៖ ដែលស្គាល់ឈ្មោះពួកគាត់?

ជឿន ៖ អត់ទេ គេមិនដែលឲ្យយើងនៅស្គាល់ចាំ នេះសុទ្ធតែឈ្លបគេមិនដឹងពីណាពីណែ ។

ធានី ៖ តែការងាររបស់ពូកងចល័ត ធ្វើការងារអីខ្លះទៅ?

ជឿន ៖ តាំងពីដំបូងទីគេឲ្យកាប់ចំការៗរួច គេឲ្យដាំម្នាស់ ដាំដំឡូង ធម្មតារួចពីនឹងទៀត ។

ធានី ៖ អីទៀត?

ជឿន ៖ ដាំចំការ ដំឡូងប៉ុននឹង ។

ធានី ៖ រហូត ឬក៏?

ជឿន ៖ ដាំដំឡូងហើយ បន្តមកទៀត គេឲ្យយើងទៅច្រូតស្រូវ ។ ដាំម៉ារយៈទេ ឲ្យទៅច្រូតស្រូវ ។ ដល់ច្រូតស្រូវមិនទាន់បានរួចផង ឲ្យអ្នកឯងទៅលើកទំនប់ៗរួចហើយ មិនទាន់ឲ្យយើងដឹងថាយូរប៉ុន្មាន ឲ្យយើងដាំចំការណាទៀត អត់ឲ្យយើងនៅបានម៉ាកន្លែង ខ្ញុំមិនដែលនៅម៉ាកន្លែងរហូត ។

ធានី ៖ ដឹងហេតុអីបានគេអត់ឲ្យពូនៅម៉ាកន្លែង?

ជឿន ៖ មិនដឹងរឿងអីគេដែរ ផ្លាស់ប្តូរៗមេវាមានប្រធានក្រុមប្រធានអី វាទូទៅអាពួកចល័តនឹង ។ ហើយខ្ញុំអត់មានដែលដឹងរឿងនិយាយប្រាប់ តែខ្លាស់ងាប់ហើយ ខ្ជិលបណ្តោយធ្វើតាមដែលយើងគួរតែធ្វើទៅកើតចេះតែធ្វើ ។ យើងអត់មានខ្វាស់គេបាន ដល់ពេលនោះ ព្រោះបើយើងខ្វាស់ក៏ងាប់ដែរ តាមណាដែលយើងអាចធ្វើបានធ្វើទៅ ។

ធានី ៖ ពូធ្លាប់ដូចថាព្យាយាមយកចិត្តអ្នកអស់នឹង ឬយ៉ាងម៉េច?

ជឿន ៖ នែក! អត់ព្យាយាមយកចិត្តពួកអស់នឹងទេ ខ្ញុំព្យាយាមតែការងារ បើថាឲ្យធ្វើប៉ុនណា ខ្ញុំធ្វើប៉ុននឹងឲ្យតែរួចចប់ហើយ ។ ហើយខ្ញុំអត់មានបញ្ចេញមតិសួររឿងមតិថាខ្ញុំអត់ចេះនិយាយ ចប់រឿង ខ្ញុំអត់មានឲ្យយោបល់គេ ។

ធានី ៖ ចុះដូចថាពួអ្នកថ្មីចឹង គេអត់មានស្រាវជ្រាវពូ?

ជឿន ៖ គេស្រាវជ្រាវដែរ គេចោទខ្ញុំសុទ្ធស្អីធំៗ ដល់ចុងក្រោយការងារខ្ញុំដែលខ្ញុំអនុវត្តការងារគ្រប់ គ្រងការងារនឹងបានទៅ រួចខ្លួន ។ យកការងារខ្ញុំដូរដោះរឿងរ៉ាវនឹងចោទប្រកាន់នឹងរួច កុំអី ខ្ញុំស្លាប់ដែរ ។

ធានី ៖ គេចោទថាម៉េចខ្លះ?

ជឿន ៖ គេចោទថា យើងមន្ត្រីៗការ វានិយាយប៉ុននេះ សុទ្ធខ្មាំងលន់ នល់ គេដេរតែចេះ ។

ធានី ៖ អ្នកណាគេចាំទេ?

ជឿន ៖ ពួកអានឹង សុទ្ធតែឈ្លបវា ពួកវានឹងចុះដូចខ្ញុំនិយាយចឹង អាពាយ័ព្យនឹងវាងាប់អស់ហើយ ។

ធានី ៖ តែស្គាល់ឈ្មោះគាត់ទេ?

ជឿន ៖ អូ! អត់ដឹងទេ មិនដឹងឈ្មោះអី ឈ្មោះគេមិនដែលឲ្យយើងចល័តចាំស្គាប់ទេ ហើយអាប្រធានឈ្លបដែលនៅជុំខ្ញុំមួយ នៅបានម៉ាថ្ងៃ គេវ៉ៃចោលបាត់ នៅស្រុកខ្ញុំ ។

ធានី ៖ ស្គាល់ឈ្មោះគាត់?

ជឿន ៖ អត់ស្គាល់ ស្គាល់មិត្តភ័ក្តខ្ញុំអ្នកថ្មីដូចគ្នាទេ ក្រៅពីនឹងអត់ស្គាល់ ។

ធានី ៖ អ្នកណាខ្លះដែលនៅជាមួយពូ ថ្មីៗ?

ជឿន ៖ ថ្មីខ្ញុំ នៅជាមួយខ្ញុំ តែឥឡូវអា២-៣នាក់នឹងទៅបាត់យូរហើយ ឈ្មោះអាមួយឈ្មោះអាផាង១ស្លាប់បាត់ទៀតហើយ វាធ្វើទាហានដល់ពេលនេះគ្រោះថ្នាក់រាលកាំភ្លើងទៅងាប់យូរណាស់ ដឹងប៉ុននឹងចប់ហើយ ។

ធានី ៖ ចេះដូចថាពេលពូធ្វើចឹង ធ្វើការធ្វើចំការ អត់មានធ្វើស្រែធ្វើអី?

ជឿន ៖ លើកទំនប់ដូចខ្ញុំនិយាយចឹង ទី១រួចពីស្រែគេឲ្យលើកទំនប់ៗបានតិចទៅ ដូចខ្ញុំថាលើកទំនប់ត្រពាំងថ្មនេះ បានតិចទៅ បើគេដកពីលើកទំនប់ត្រពាំងថ្មគេមកឲ្យលើកប្រឡាយប្រាសាទ៥ នេះ បានគេមកនៅគព្ភដើមៗគេឲ្យនៅអគ្គភាពទេ គេឲ្យនៅចំការអូរត្បែង១នឹងគេឲ្យដាំបន្លែ បានតិចទៅគេដកឲ្យទៅលើខ្នងទំនប់ទៀតទៅ ។

ធានី ៖ ពូអត់ចាំមេអស់នឹង ដូចថានៅត្រពាំងថ្មឈ្មោះអី មេនៅអូរប្រាសាទឈ្មោះអី?

ជឿន ៖ អូ! អត់ដឹងណាជាណែ ម៉ាឈ្មបអានេះម្តង អានោះម្តងទាល់តែយើងប្រជាជនថ្មីគេមិនដែល ឲ្យដឹងការពិតទេ ។

ធានី ៖ ចឹងពូអត់ដឹងទេ?

ជឿន ៖ អត់ដឹងទេ គេមិនប្រាប់ ។

ធានី ៖ គ្រាន់ដឹងអ្នកមកពីបូព៌ា អ្នកមកពីបស្ចឹម?

ជឿន ៖ អានឹងដឹង ។

ធានី ៖ យ៉ាងម៉េចអ្នកមកពីបូព៌ា?

ជឿន ៖ អានឹងមុនដំបូងពាយ័ព្យវាកាន់ការដំបូង ដែលខ្ញុំនៅដំបូងគឺពួកវាកាន់ការ បន្ទាប់មកយក ពាយ័ព្យបន្តបាត់ មិនដឹងទៅណាមកណែទេ ។

ធានី ៖ ទៅអស់?

ជឿន ៖ ទៅអស់ បាត់ ចាប់បោះលើឡាន ដែលទៅនៅអី ។

ធានី ៖ ពូថាម៉េច អ្នកបោះលើឡានដូចអ្នកប្រជាជនថ្មីធ្វើម៉េច កាលនឹងពូនិយាយមិញ?

ជឿន ៖ ហ្នឹងហើយ អ្នកចាប់បោះលើឡាន ដូចរឿងមួយគេធ្វើដូចថាអត់មានស្អីពិបាកប្រកែក ប្រណាំងជាមួយវា វាបោះដូចបោះផ្លែចេក ដូចបោះអុសអីចឹង អានឹងអ៊ីដែលអត់មាន ប្រកែកបាន គេនិយាយធ្វើម៉េចទៅតាមចិត្តគេ អានឹងដូចមេធ្លាប់ស្គាល់ដូចឈ្មោះ លឿង ដែលខ្ញុំថានឹង អានឹងគាត់ស្លាប់ទៅហើយ មិនបាច់និយាយទេ គាត់នឹងនោះ ។ អានឹងប្រធាន អង្គភាពនឹង ។ ដល់ក្រោយមកទៀត និរតីគេកាន់ការ បស្ចឹម ៗ ហើយ និរតីគេគៀបពីលើ ទៀតចប់ ។ អ្នកល្អ ៗ ដែលស្គាល់យើងការងារល្មមដែលថាស្គាល់យើង ដូចថាយើងសកម្ម ការងារគេជួយយើង ។

ធានី ៖ ចឹងអ្នកដែលគេជួយពូនឹងត្រូវគេយកទៅ?

ជឿន ៖ សម្លាប់បាត់ មួយឈ្មោះ លឿង មិញ ។

ធានី ៖ លឿងនឹង គាត់ងារជាអី?

ជឿន ៖ ប្រធានដែលអង្គភាព ប៉ុលឿងនឹង ។

ធានី ៖ អង្គភាពអីគេ?

ជឿន ៖ អង្គភាពគពដើម ចល័ត ។

ធានី ៖ ចឹងអង្គភាពចល័តគពដើមនឹង គាត់ជួយពូ ជួយអ្នកណាដែលធ្វើការងារសកម្ម ជួយ?

ជឿន ៖ ជួយដូចថាយើងធ្វើការងារអ៊ីដែលធ្វើទៅត្រឹមត្រូវ ស្របទៅ គេអត់ធ្វើបាបយើងទេ មិនមែនដូចពួកអានេះ យើងចេះខ្លាំងថាយើងចេះ ដល់យើងល្ងង់ថាយើងមិនសកម្ម ។ អារឿងចំនុចត្រង់នេះ គេចាំចាប់កំហុសយើង គេមិនមែនចាំអី បើថាអ្នកល្អជា អ្នកនឹងសកម្មដឹងសកម្ម ហើយបើអ្នកមិនល្អវាដឹងថាអានឹងម៉េចៗ ។

ធានី ៖ ចឹងពូក៏សម្រេចចិត្ត យើញអ្នកលឿងនឹងខាងភូមិភាគបស្ចឹមមកចាប់យកគាត់ទៅបាត់ទៅ?

ជឿន ៖ បាទ! ចប់រឿងប៉ុននឹង ។

ធានី ៖ ចឹងអ្នកមកក្រោយជួយពូទៀត?

ជឿន ៖ ក្រោយចប់...មានអីវាបានតិចយើងចប់បណ្តោយ ។

ធានី ៖ ចឹងបន្ទាប់ពីពូលឿងដែលគេចាប់យកទៅ អ្នកខាងបស្ចឹមមក ឬក៏ខាងនិរតីមក?

ជឿន ៖ បស្ចឹមមកមុន ។

ធានី ៖ ប៉ុន្តែអត់ដឹងអ្នកណាទេ ហើយគេចាប់បន្តទៀតទៅ?

ជឿន ៖ បស្ចឹម គេចាប់ មិនដឹងថាគេចាប់ មិនចាប់ទេ ព្រោះរឿងការពិតគេធំៗគេមិនឲ្យយើងដឹងតែគ្រាន់ថានៅក្នុងអគ្គភាពនឹង អត់ទាន់មានឃើញអ្នកណាបែកទៅណាទេ ។ ទៅរៀន ។ ដល់ ពេលក្រោយទៀត និរតីគេមកពីលើទៀតមួយទៀត វាចប់រឿងគ្នា ។

ធានី ៖ ខាងណាទៀត ពូស្គាល់និរតី?

ជឿន ៖ អូ! អត់ស្គាល់ទេ ដឹងមកពីណាពីណែ គ្រាន់គេថានិរតីៗ ។

ធានី ៖ ពូឈ្មោះពូអី?

ជឿន ៖ និរតីៗ ក៏មិនដែលទាំងឃើញមុខគេ មើលមុខគេយើងនិយាយដឹងតែខ្លួនខ្លាចតែងាប់ធ្វើការគេហៅគ្នាទៅដឹង ។

ធានី ៖ ចុះដូចថាពេលដែលពូទៅដំបូង ពូទៅលើកទំនប់ត្រពាំងថ្ម ដូចថាឃើញត្រពាំងថ្មរៀងវាយ៉ាងម៉េច?

ជឿន ៖ ដែលលើកទី១ ដែលខ្ញុំទៅលើកត្រពាំងថ្មៗជារៀងវាលធម្មតាៗ អត់មានគ្រលេគ្រលុកអីទេ វាលស្រែធម្មតា ។

ធានី ៖ ហើយចឹងធ្វើម៉េចបានចេញជាអាង?

ជឿន ៖ ចេញជាអាងទៅ វាឲ្យកងចល័តនឹង គិតពីរែកដីពីនៅខាងក្រោមមកដាក់មកធ្វើជាទំនប់តាម គំរូរបស់គេ ដឹងគំរូចេញពីត្រង់ណាត្រង់ណែ ខ្ញុំអត់ដឹងរឿងទេ គំរូគេនោះ ។

ធានី ៖ ចឹងពូនៅកងចល័តទី១ ទី២ ឬក៏?

ជឿន ៖ កងចល័តកម្លាំងទី២ ។

ធានី ៖ ពូកម្លាំងទី២ៗ គេឲ្យធ្វើអីខ្លះ?

ជឿន ៖ កម្លាំងទី២ គេឲ្យលើកដី៤ម៉ែត្រ អាទី១៦ម៉ែត្រ ៧ម៉ែត្រ ដោយសារឃើញខ្ញុំតូចហើយ
ទៅ គេដាក់ចូលក្នុងកងកុមារ ។

ធានី ៖ ចឹងពូនៅក្នុងកងកុមារទេ?

ជឿន ៖ ខ្ញុំកងកុមារ ។

ធានី ៖ មិនមែនក្នុងកង?

ជឿន ៖ កងពិសេស ។

ធានី ៖ កងចល័តទី១ដូចមីងទេ?

ជឿន ៖ បាទ! កងពិសេស ធ្ងន់ណាស់ បើមិន៤ទៅ៦ ៦ទៅ៧តាមតែវាដាក់ ។

ធានី ៖ ចឹងពូនៅកងកុមារ ពូអាចធ្វើបាន?

ជឿន ៖ ធ្វើបាន ។

ធានី ៖ ដោយសារមាឌល្អិតយោង?

ជឿន ៖ មាឌល្អិតតូច គេ ។ ធ្វើមិនបានផង ចុះអាទៅរែក៤-៥-៦គីប ទៅរែករួច?

ធានី ៖ ពូបានឃើញទេ អ្នកដែលធ្វើអត់បាន?

ជឿន ៖ ធ្វើអត់បាន គេមិនដែលសម្លាប់ឲ្យខ្ញុំឃើញទេ ដូចថាបើធ្វើអត់បានស្រាប់តែយប់ឡើងបាត់
ដូចខ្ញុំនិយាយយប់ឡើងដេកជិតៗគ្នា ស្រាប់យប់ឡើងនៅសល់សាក់កាដូ នៅសល់អីបាត់
មនុស្សមិនដឹងទៅណា ដល់ព្រឹកឡើងគេធ្វើការប្រជុំគ្នា គេថាអើយ!អា-ក អាមិត្តនេះ
មិត្ត នោះរត់ទៅបាត់ហើយ ។

ធានី ៖ គេនិយាយចឹង?

ជឿន ៖ បាទ! និយាយចឹង យើងដឹងថាម៉េច ហើយយើងភ័យខ្លួន ខ្លាចតែខ្លួនយើងដងៗ ហើយ
យើងអត់ជឿថារត់ទេ ព្រោះយើងប្រជាជនថ្មីជឿថាមិនដែលមានផ្ទះណាអ្នកនៅទេ ប្រជា
ជនថ្មីនោះ ណាប្រាកដ ។ ហើយអ្នករត់ខ្ញុំសង្កេតមើលឃើញច្រើនថ្មី ។

ធានី ៖ ប្រជាជនថ្មីទាំងអស់?

ជឿន ៖ បាទ! ច្រើនដែលថ្មី ដែលរត់ចេញ ។

ធានី ៖ គេនិយាយប្រាប់ចឹង ឬក៏ឃើញគេរត់ផ្ទាល់?

ជឿន ៖ ធម្មតាតែនៅចល័តជុំគ្នា១០នាក់ចឹង ទៅយើងដឹងថាអានេះមកពីនេះពីនោះហើយណា ដល់ពេលនោះ....ទៅអស់ ។

យើងចេះតែធ្វើទៅគ្នាខ្លះអត់ដឹងចេះចោទថាឪពុកអ្នកឯងធាហានទៅ

យកអានេះទៅវ៉ៃចោល ឬយ៉ាងម៉េចគេ ។ ហើយតាមសកម្មភាពគ្រាន់ថាតួនស៊ីមិនឆ្អែតក៏ត្រូវតែបាត់ដែរ ។ បានខ្ញុំថាវាផ្តាច់ការហួសហេតុ ។

ធានី ៖ ពេលដែលពូដឹងថា ចាំសង្កេតមើលទាំងអស់?

ជឿន ៖ ខ្ញុំសង្កេតមើល ចាំមើលចឹង តែអត់ធ្វើម៉េង ខ្ញុំសុខចិត្តថាដឹកតែទឹកក៏ខ្ញុំ គេឲ្យខ្ញុំធ្វើម៉េចក៏ស៊ូទ្រាំ ខ្ញុំដឹងថាបើមិនទ្រាំក៏ដឹងថាស្លាប់ ទ្រាំដឹងថារស់ ហើយយើងកុំនិយាយនៅឲ្យស្ងៀម ។

ធានី ៖ ចុះពូមានប្រាប់ដូចថាមិត្តភ័ក្តិរបស់ពូផ្សេងទៀត ដែលនៅក្នុងកងជាមួយគ្នាប្រាប់ថាឲ្យទ្រាំអី ចឹងទៅ?

ជឿន ៖ ប្រាប់គេ តែមិនហ៊ាននិយាយខ្លាំង មិនទុកចិត្តគ្នាឯង មិនអាចទុកចិត្តគ្នាឯង ខ្លាចគ្នាឯងវាផុយមាត់ដែរ ម្ល៉ោះហើយចេះប្រយ័ត្នអើយ!កុំនិយាយច្រើន ប្រាប់ប៉ុននឹងអស់ទៅ កុំសួរដឹងរឿងច្រើន ធ្វើតែការងារ ហ៊ាននិយាយរឿងអីផ្សេង អត់ហ៊ាននិយាយ ព្រោះគេចោទថាខ្ញុំចេះ ចោទចេះ ខ្ញុំអត់ចេះទេ ។ ហើយធម្មតាតែឃើញយើងធ្វើសកម្មភាពអីឡើងចេញជារូបរាង ដូចជាដំណាំឲ្យយើងប្រើយើងធ្វើបាន តែធម្មតាការងារព្យាយាមរបស់យើងទេដើម្បីចៀសវាងគ្រោះថ្នាក់ដល់អាយុជីវិតយើង ។ បើយើងមិនខំព្យាយាមធ្វើទេ យើងដឹងថាស្លាប់ដែរ បើសិនយើងធ្វើមិនបានផែនការរបស់គេយើងក៏ត្រូវតែស្លាប់ដែរ ។ ម្ល៉ោះហើយយើងត្រូវតែខំ អ៊ីៗដែលយើងគេដាក់ឲ្យចេះខំធ្វើ ដូចរែកដី៤ម៉ែត្រ ចេះខំធ្វើទៅរួចមិនរួចចេះខំធ្វើទៅ ម៉ោង១ម៉ោង២យប់រួចទៅតាមរួច បើមិនរួចចេះតែរែកវាស់ព្រឹក ។

ធានី ៖ តែពេលខ្លះពូធ្វើអត់រួចដែរ?

ជឿន ៖ រែកវាស់ព្រឹក អត់មានមិនរួចទេ ។

ធានី ៖ ចុះពូទៅរែកតាំងពីស្មានណា?

ជឿន ៖ ម៉ោង៣ងើប ម៉ោង១២យប់បានឈប់ ។

ធានី ៖ ៤ម៉ែត្រគីបនឹង?

ជឿន ៖ ៤ម៉ែត្រគីបមិនងាយទេ ៤ម៉ែត្រគីបឡើងទំនប់មិនងាយទេ ។

ធានី ៖ ៤ម៉ែត្រគីបឡើងទំនប់ទៀត?

ជឿន ៖ បាទ! ឡើងទំនប់ មិនមែនដឹកដើងទំនប់ ដឹកចង់១០០ម៉ែត្រពីជើងទំនប់ ។

ធានី ៖ ចឹងពេលពូទៅដល់នឹង ពូធ្វើទំនប់តាំងពី?

ជឿន ៖ តាំងពីអត់ តាំងពីទើបនឹងលើកដីបោះដូចធ្វើភ្លឺចឹង ។

ធានី ៖ កាលនឹងតាំងឆ្នាំប៉ុន្មានដែរ ពូចាំបានទេ អាចចាប់ផ្តើមធ្វើដំបូង?

ជឿន ៖ ហ៎! វាភ្លេចហើយឆ្នាំប៉ុន្មាន វាភ្លេច មិនគិតពីរឿងថ្ងៃខែឆ្នាំ ។

ធានី ៖ ចាំមើលពូមៀសមក៧៥ខែវស្សា ដល់ពេលខែប្រាំងនឹងចូល៧៦?

ជឿន ៖ អូ! ប្រហែលក្នុងឆ្នាំ៧៦ដឹង ព្រោះ៧៧ព្ទុសួរពួកនឹងវៃចូលក្រែកចូលអីហើយ ។

ធានី ៖ ម៉េចបានពូ?

ជឿន ៖ និយាយវាជាពិសេសគ្នាវា អាទាហានៗវានិយាយ ។

ធានី ៖ ពូលួចស្តាប់?

ជឿន ៖ អត់លួចស្តាប់ទេ ប៉ះណាគេទុកចិត្តយើង ប៉ះណាដូចថាគេមិនចេះរករឿង យើងមិនចេះធ្វើស្អី យូរៗគេនិយាយគ្នាគេ ។

ធានី ៖ ពូបានព្ទុ?

ជឿន ៖ គេថា អូ! អាយួនវៃដល់ក្រែកហើយ ។ សួរអត់ចេះមាត់ទេ ចេះតែប្រុងខ្លួនហើយ អត់ហ៊ានចៀតទេ ខ្លាចគេថាឯងយកការណ៍ទៀត ។ ទៅដល់គ្នាគេបើករាដ្យូព្ទុកោក ។

ធានី ៖ គេបើកព្ទុៗ?

ជឿន ៖ ហ្នឹងបើកព្ទុៗ ។

ធានី ៖ ចឹងពូធ្វើទំនប់នឹងនៅឆ្នាំ៧៦?

ជឿន ៖ បាទ! ប្រហែលជាពេលនឹងឯង ។

ធានី ៖ ៧៦ពេលណាបានធ្វើទំនប់នឹងហើយ?

ជឿន ៖ ហ៎! ទំនប់នឹងចូលម៉ាឆ្នាំនឹងបានរួច ព្រោះប្រហែលជាខែប្រាំងគេឲ្យលើកប្រឡាយនេះប្រាសាទ៥ឈើទាល ។ គេអត់ឲ្យនៅយូរ ព្រោះវាដូរកម្លាំងវត់គេរកម្លាំង គេអត់ឲ្យយើងនៅម៉ាកន្លែង ។

ធានី ៖ និយាយទៅទំនប់នឹងធ្វើរហូត?

ជឿន ៖ ធ្វើរហូតទាល់តែរួចរបស់គេ ។

ធានី ៖ ប្រហែលឆ្នាំប៉ុន្មាន ដូចថាដាក់ដែនការឆ្នាំប៉ុន្មាន បានគេធ្វើទំនប់នឹងហើយ?

ជឿន ៖ ទេ! ដូចអត់មាននិយាយ ខ្ញុំមិនដឹង ។

ប្រពន្ធ ៖ ទេ! ទំនប់នឹងប្រហែលជា៣ខែប៉ុននឹង ទំនប់នោះ៣ខែប៉ុននោះឯង គ្មានដូរណាទៀតទេ វៃឲ្យរួចហើយមក អត់មានដកកម្លាំងអាទី២ទេ ។

ជឿន ៖ នៅសំអាតទៀតនោះ នៅអ្នកទប់ជើងក្រោម ។

ប្រពន្ធ ៖ នៅអ្នកដាំស្លទេ ។

ជឿន ៖ នៅអានឹងទៀតយើងថារួចម៉េចបាន ព្រោះយើងដកបាត់ទៅហើយ ។

ធានី ៖ ព្រោះយើងធ្វើតែរូបរាងគ្រោងវា?

ជឿន ៖ រូងរាង ធ្វើជាគម្រោង គេគ្រោងហើយ គេដកយើង ។

ធានី ៖ ចុះពូដឹងថាគេចាប់ផ្ដើមសម្ពោធន៍ទំនប់នឹង ពេលណាទេ?

ជឿន ៖ ទេ! សម្ពោធន៍ពេលហ៊ឹង កាលនោះ ពេលហ៊ឹងទៅសម្ពោធន៍ដែរ ។

ធានី ៖ ហ៊ឹង?

ជឿន ៖ ហ៊ឹង ។ កាលនោះហ៊ឹងនឹង ជាស្អីភូមិភាគ ។ ប៉ុ ហ៊ឹង គណៈភូមិភាគ ប៉ុ ហ៊ឹងទៅសម្ពោធន៍ ។

ធានី ៖ គណៈភូមិភាគ គណៈស្រុក គណៈតំបន់?

ជឿន ៖ ទេ! ភូមិភាគ ។

ធានី ៖ គណៈតំបន់?

ជឿន ៖ ដៀល គណៈតំបន់ ។

ធានី ៖ បើគណៈភូមិភាគតាញឹម?

ជឿន ៖ អូ! តាញឹមនឹងហើយ តំបន់ ។ ព្រោះរឿងនឹងខ្ញុំមិនដឹងថាស្អីទេ តែគ្រាន់ថាគេមកមេធំៗចឹង យើងមិនដឹងថាតំបន់ ឬយើងអី ។

ធានី ៖ តែគ្រាន់ដឹងហ៊ឹង ហើយនឹងដៀល?

ជឿន ៖ បាទ! ហ៊ឹង ដៀល ។

ធានី ៖ ប្រហែលជានៅក្នុង៧៧អីដែរ?

ជឿន ៖ ហ៊ឹងហើយ ចុងក្រោយ ។

ធានី ៖ ព្រោះ៧៨គេចាប់គាត់អស់ហើយ ចាប់ហ៊ឹង ចាប់ដៀល គ្មាននៅ?

ជឿន ៖ អានឹងកាលគេសម្ពោន៍ គេនៅនឹងឯង ។

ធានី ៖ ហើយគាត់និយាយថាម៉េចខ្លះ?

ជឿន ៖ អូ! អត់មានស្ដាប់គេបានទេយើង ។

ធានី ៖ ចុះពូចូលរួមសម្ពោធន៍ដែរ?

ជឿន ៖ ចល័តទាំងអស់ នៅឈរស្តាប់ តែយើងនៅឆ្ងាយៗហ៊ានទៅបៀតគេ អាគេនិយាយទៅតែគ្នា ។

ធានី ៖ ហើយចឹងម៉េចបានពូដឹងថាហ៊ីង ហើយនឹងជៀលនឹង អ្នកសម្ពោធន៍នឹង?

ជឿន ៖ ទេ! ដល់ពេលចល័តទាំងអស់គេឲ្យទៅមើល គេបើកសិល្បៈគេ ។ រាត្រីសិល្បៈគេមិនឲ្យមើល ។

ធានី ៖ ឲ្យមើលគេ?

ជឿន ៖ ឲ្យមើលគេនិយាយខ្ទះគ្នាគេ ដល់ពេលគេនិយាយតែគ្នា គេមិនឲ្យយើងស្តាប់ដឹងថាម៉េចៗ ។

ធានី ៖ ចង់និយាយថាម៉េចបានពូដឹងថា អ្នកនេះឈ្មោះជៀល អ្នកនេះឈ្មោះ ហ៊ីងអីចឹង?

ជឿន ៖ វាធម្មតា វមិនដុតពីគេប្រាប់ទេ មិនដុត តែខ្ញុំអត់ច្បាស់ថា គណៈតំបន់ គណៈភូមិភាគមិញ មិនច្បាស់ទេ ព្រោះយើងមិនមែនទៅសង្ស័យ ។

ធានី ៖ តែគ្រាន់ដឹងថា២នាក់នឹង ចុះក្រៅពី២នាក់នឹង អត់មានអ្នកផ្សេងទៀត?

ជឿន ៖ អូ! អត់ដឹង ។

ធានី ៖ មានច្រើន ប៉ុន្តែអត់ដឹង?

ជឿន ៖ អត់ដឹងមិនដឹងណាគេ យើងអត់ស្គាល់ ។

ធានី ៖ អត់ស្គាល់គាញឹម?

ជឿន ៖ ហ៎! គាញឹមតែឈ្មោះៗ ក៏មិនដែលឃើញមុខផង ។ សម្ពោធន៍ គេនិយាយសម្ពោធន៍ ។

ធានី ៖ ចាំឆ្នាំ ប្រហែល?

ជឿន ៖ ទេ! អត់ចាំៗ ។

ធានី ៖ ខែវស្សា ខែប្រាំង?

ជឿន ៖ ទេ! ខែប្រាំងដូចជាប្រូតរួច ព្រោះមិនទាន់មានទឹកផង កាលនឹងវានៅខែប្រាំងនៅឡើយ ។

ធានី ៖ ចឹងប្រហែលជាអាច៧៧?

ជឿន ៖ ហ្នឹងអានឹង វាមិនមែនឲ្យយើង ។ គ្មានគិតទេ គ្មានគិតណាម៉េចៗ គិតពីញ៉ុកត្រចៀកទាំងអស់ការពារប្រយោជន៍ខ្លាចស្លាប់ខ្លួនយើង ។

ធានី ៖ ពូឃើញផ្ទាល់ភ្នែក?

ជឿន ៖ អឺ! បើមិនឃើញម៉េច រឿងឃើញ ។

ធានី ៖ ចុះពូធ្វើទំនប់នឹង តើពូធ្វើយ៉ាងម៉េច វែកយ៉ាងម៉េច ឬមឹងមិញសុទ្ធតែរត់ឡើង ហើយអត់មានពេលសម្រាកៗយ៉ាងម៉េច គេស្តីឲ្យថាឲ្យយ៉ាងម៉េច?

ជឿន ៖ គេថាបេះ បើថាពេលវែកទី១ប្រយ័ត្នអារឿងខ្សែបន្ទីរ ទី២ប្រយ័ត្នដងវែកតែដាច់ខ្សែបន្ទីរ ខ្លាំង គេនិយាយរួចហើយ បាក់ដងវែកខ្លាំង បាក់ចប គឺខ្លាំងទាំងអស់អាពានឹងៗ រត់ស្វាត់ កុំរត់ប្រឡែងគ្នា កុំរត់ស្រែកឡូឡា ខ្លាចមិនរួចៗ គិចថាវែកមិនទាន់រួចទៅផ្អែកដើមឈើអត់ បានទៀត ប្រមាណម្តង២ដងៗ

ធានី ៖ អាអស់នឹងសុទ្ធតែមានគោលការណ៍គេ ឬក៏ជារបស់គេត្រូវតែចឹង ឬយ៉ាងម៉េច?

ជឿន ៖ អត់ដឹង ដឹងជាគោលដៅ ដឹងថាទិសដៅរបស់អ្នកណាបញ្ជាឲ្យធ្វើចឹងខ្ញុំក៏មិនដឹងដែរ ឬក៏អ្នកដែលកាន់កាប់នឹង គំរាមឲ្យយើងធ្វើឲ្យរួចឲ្យគេ ឬក៏គេយ៉ាងម៉េច ការងាររលាក់ការណ៍របស់គេៗ យើងមិនអាចដឹងស៊ីជំរៅចឹងទេ អាត្រង់នឹងៗ តែដឹងថាអ្នកណាអ្នកចន្លុះឲ្យធ្វើចឹងមិន ដឹងអ្នកណា អ្នកប្រើឲ្យធ្វើចឹង ក៏យើងមិនអាចដឹងៗ

ធានី ៖ ចុះដូចថាអ្នកណាជាប្រធានក្រុម ប្រធានកងអីចឹង នៅពេលលើកទំនប់?

ជឿន ៖ ប្រធានក្រុមប្រធានកងបាត់ឈ្មោះ មិនដឹងអាណាអាណែវាខ្ញុំអត់ចាំឈ្មោះដែរ វាយូរយាំងហើយ បាត់មិនដឹងណាណែៗ

ធានី ៖ តែពូនៅចាំឈ្មោះទេ?

ជឿន ៖ ទេ! អត់ចាំទេ អារឿងណាខ្ញុំច្បាស់ខ្ញុំប្រាប់ បើមិនច្បាស់អត់ប្រើទេៗ

ធានី ៖ ចុះពូកាលនឹង មានឮឈ្មោះយាយថែម?

ជឿន ៖ អារឿងយាយថែម ឮតែឈ្មោះ តែមិនដែលឃើញរូបរាងប្រាដកថាយ៉ាងម៉េចទេ ថាបើយាយថែមនឹងមកឈរ-ប្រជារាស្ត្រផ្ទាល់ក៏មិនដែរៗ

ធានី ៖ ដែលឮឈ្មោះគាត់យ៉ាងម៉េច?

ជឿន ៖ យាយថែមនឹងដូចជាគេថាធ្វើស្អី មិនដឹងធ្វើស្អីមិនដឹងរឿងគាត់ផង យាយថែមខ្ញុំអត់ច្បាស់លាស់ទេ ខ្ញុំមិនហ៊ានថានិយាយប្រាប់ៗ

ធានី ៖ ចឹងចង់សួរពូថា ពេលដែលពូទៅលើកទំនប់នឹង រឿងហូបចុកអីយ៉ាងម៉េចដែរ?

ជឿន ៖ អឺ! រឿងហូបចុកអីអត់ប្រាកដទេ ទី១ដូចខ្ញុំនិយាយចឹង តែហូបចុកដាំបាយរុយរោមចោលទៅ ហើយប្រហុកម៉ាគីឡូស្ងោរទឹកម៉ាខ្ទះទៅ បើកងអ្នកឯងឡើងរួច វែករួចអ្នកឯងទៅហូបទៅ បើអ្នកឯងវែកមិនរួចអត់ៗ

ធានី ៖ អត់បានហូបទៀត?

ជឿន ៖ អត់បានហូប បាយនឹងក្រៀមប៉ុន្មានក្រៀមទៅ រុយរោមប៉ុនណារុយរោមទៅ ។

ធានី ៖ ចឹងវាមានជម្ងឺអី?

ជឿន ៖ អូ! អាជម្ងឺចេះតែមានរាគរុះងាប់ដោយសាររឿងនឹងឯង វាអត់មានអនាម័យៗ អត់មានទាល់តែសោះ ។

ធានី ៖ ចឹងអ្នកដែលរែកនៅនឹង ភាគច្រើនស្លាប់ដោយសារជម្ងឺរាគរុះ?

ជឿន ៖ ស្លាប់រាគរុះ ដោយសារជម្ងឺពោះវៀន ។

ធានី ៖ អត់មានពេទ្យ?

ជឿន ៖ អារឿងពេទ្យគេឲ្យតែថ្នាំអាចមន៍ទន្សាយទៅធ្វើម៉េច ហើយលេបម៉េចថ្នាំអាចមន៍ទន្សាយហើយថ្នាំវីតា យកមកចាក់ៗយ៉ាងម៉េច ។

ធានី ៖ មានពេទ្យគេចាក់ដែរ?

ជឿន ៖ ចាក់តាមនឹងដែរ គេសុំចេះឲ្យតែត្រង់អ្នកឯងលេបម៉េចបាត់លេបទៅ ។ លេបម៉េចបាត់បើថ្នាំប៉ុននឹងៗ ហើយយើងអាហារហូបចុកវាគ្មានអនាម័យ ធ្វើម៉េចបាត់អាពួប៉ាវ៉ាស៊ីតនឹង វាអត់មានទេ ទៅជាអីកូលីដូចអារឿងគេតែងនិយាយ ។ ព្រោះវាចឹង ទៅនិយាយជម្ងឺពោះវៀនមកឈាមទាំងដុំៗ ស្លាប់ ។

ធានី ៖ ចឹងប្រជាជននៅនឹងភាគច្រើនមានប្រជាជនប៉ុន្មាននាក់ ដែលត្រូវឈឺ?

ជឿន ៖ អូ! អានឹងយើងអត់ដឹងទេ គេមិនឲ្យយើងដឹងទេ ។

ធានី ៖ តែពេលពូទៅធ្វើការនឹង ពូឃើញយ៉ាងម៉េចខ្លះ?

ជឿន ៖ ឃើញម្តងម្នាក់ៗឈឺចឹងទៅ តែខ្ញុំប្រយ័ត្ន ខ្ញុំដាំទឹកផឹក ខ្ញុំដឹងរឿង អត់ដែលផឹកទឹកឆៅទេទោះយ៉ាងណាក៏ខ្ញុំត្រូវដាំផឹកខ្លួនខ្ញុំ ។

ធានី ៖ ចុះមានទឹកគ្រប់គ្រាន់ដែរ?

ជឿន ៖ ទឹកគេទៅរែកនៅភ្នំកូនខ្វែង អាទឹកល្អក់កកនឹងទៅ ។ ប៉ះថ្ងៃណាអត់ទៅ ទៅបឹតអាទឹកកក់ ។ បើយើងមានគំនិតយើងដាំគេអត់ឃាត់ទេ បើយើងដាំម៉េចដាំទៅឲ្យតែយើងមានពេល ។ អានឹងគ្រាន់រឿងដាំ យើងលួចដាំទៅ ។

ធានី ៖ ពេលដែលពូទៅលើទំនប់នឹង ពូទៅស្នាក់នៅកន្លែងណា?

ជឿន ៖ អូ! អានឹងទៅស្នាក់តាមវាលស្រែ អត់មានរឿងផ្ទះទេ ។

ធានី ៖ អត់មាននៅតាមភូមិ?

ជឿន ៖ អូ! អត់មានទេ ដេកក្នុងបង្កីរក៏មាន ។

ធានី ៖ គេឯនៅកន្លែងការដ្ឋាននឹងម៉ែង?

ជឿន ៖ បាទ! លើកត្រង់ណាដេកត្រង់នឹង គេគ្រាន់ធ្វើជំរំតិចៗនឹង អាផ្ទះរបៀបផ្ទះខ្មែរលើនឹង អាយាប់ដល់ដីនឹង ចូលសិកៗយើងទៅ ។ គេមិនមែនឲ្យយើងមានសិទ្ធិធ្វើស្អីបាន យើងដេកក្រោមអានឹងអត់បានទៀត ។

ធានី ៖ តែអានឹងបានតែអ្នកប្រជាជនថ្មីដូចពូ ឬក៏ទាំងអត់គ្នា?

ជឿន ៖ អារឿងត្រង់នេះ វាចាស់ វាថ្មី វាច្របូកច្របល់ គេអត់ដែលប្រាប់យើង អាពួកណាប្រជា ជនចាស់ ភាគច្រើនគេ ការងារគេផ្សេងទៅទៀត ដូចថាគេធ្វើឈ្លប ឬក៏គេធ្វើមេកង មេអីដូរផ្លាស់គ្នាចុះឡើង ។

ធានី ៖ ក្រែងពូថា អ្នកនៅក្នុងលើទំនប់នឹង អ្នកខ្លះថ្មី អ្នកខ្លះចាស់ធ្វើជាមួយគ្នា ។ ចឹងការគេង ការហូបអីជុំគ្នាដែរ?

ជឿន ៖ ទេជុំគ្នាអត់មានដូរផ្លាស់អីទេ អាប្រធានក្រុម ប្រធានកងណា ឃើញតែស៊ីចុកបុកទំពាជាមួយគ្នាឃើញតែចឹង ដូចអត់ទេ ។ ដល់អាប្រធានកងធំ ខ្ញុំអត់ដែលបះទេ ។ តែត្រឹមកង ៣០ កងអីនេះឃើញនៅជាមួយ ស៊ីអាទឹកប្រហុកដូចគ្នា ស្អីដូចគ្នា ។

ធានី ៖ ហើយមានជម្ងឺដូចគ្នាដែរ?

ជឿន ៖ អឺ! ដេកពេទ្យដូចគ្នានឹង រត់ចោលផ្ទះ រត់ចោលសម្បែងដូចតែគ្នានឹង ។ អាពួកនេះ ភាគច្រើន បើខ្ញុំសាក់សួរមែកទែន គ្រាន់គ្នាអ្នកនៅនេះទេ តែគ្នាមិនបានចូលក្នុងជីវំដោះដែរ ។ អ្នកទៅរៀនទៅសូត្រពីណាពីណែទៅ ដូចថាជីវភាពគ្រួសារគេនៅទីផ្សារគេ ។ ដល់ពេលស្រុកគេដែលចឹងទៅ គេត្រឡប់មកចូលភូមិឋានយើង ដល់ចឹងគេចល័តតាមយើងតាមគេ តែគ្រាន់ថាគេអ្នកនៅនឹងគេស្គាល់ចឹង ដែលឲ្យយើងភ្នំពេញធ្វើមិនដែលស្គាល់ចរិតយើងផង ខ្លាចយើងដឹកនាំទៅណាណែ ។

ធានី ៖ ពេលពូនៅនឹងមានពួកអ្នកធ្វើការ ឬមន្ត្រីអីពីភ្នំពេញទៅជាមួយគេ?

ជឿន ៖ ដូចអត់មានបះចល័តក្មេងៗចឹងអត់បះទេ បើចល័តវ័យកណ្ដាលបះហើយ ។

ធានី ៖ តែពូអត់បានដឹង?

ជឿន ៖ អត់ដឹងទេ ព្រោះគេចល័តវ័យកណ្ដាល ពួកអ្នកធ្វើការភ្នំពេញត្រូវប៉ះ តែដល់ខ្ញុំកុមារវាដែលមានប៉ះ ។

ធានី ៖ កាលនឹងពូអាយុប៉ុន្មានដែរ បានជាគេចាត់ទុកចូលកងកុមារ?

ជឿន ៖ កាលនោះ ខ្ញុំវាតូចដែរ ខ្ញុំអាយុ២០លើសតិច តែតាមមែនទែនយើងមិនមែនកងកុមារទេ គ្រាន់ខ្ញុំតូច ។

ធានី ៖ អាយុ២០ចឹងគេចាត់ចូលកងកុមារ?

ជឿន ៖ បាទ! ចូលកងកុមារ ហើយយើងស្គមតូចផង ។

ធានី ៖ ហើយគេស្រាវជ្រាវដែរ?

ជឿន ៖ គេស្រាវជ្រាវដែរ គេមិនមែនស្រាវជ្រាវផង ដូចថាយើងតូចទៅ អត់បាយយើងស៊ីតែបបរស្គមទៅចឹងទៅ ក៏គេថាប្រើៗ ។

ធានី ៖ មកពីពូខំប្រឹងធ្វើការឲ្យគេ ហើយគេចង់ទុក?

ជឿន ៖ អេ! អារឿងនេះ បើយើងមិនប្រឹងធ្វើការងារ ដឹងថាយើងស្លាប់ហើយ ព្រោះដំណើរដូចខ្ញុំនិយាយបើខ្ចាស់តិចងាប់ យើងសុខចិត្តដូចថាដោយសារការងាររបស់យើង កុំឲ្យស្លាប់គេវៃធ្វើបាប ។

ធានី ៖ ចុះពូដឹងថា អ្នកដែលស្លាប់នៅទំនប់ចឹង គេយកទៅកន្លែងណា?

ជឿន ៖ អូ! អារឿងនឹង គេអត់ដែលប្រាប់យើងទេ លាក់ ។

ធានី ៖ ហើយពូបានព្ទ?

ជឿន ៖ អូ! គេមិនដែលឲ្យយើងដឹង គេនិយាយតែរត់ម៉ាមាត់ៗ គេអត់មាននិយាយស្អីទេ អ្នកឯងរត់ទៅផ្ទះបាត់ហើយ ។

ធានី ៖ តែបើចិត្តពូៗថាអ្នកអស់នឹងទៅណា?

ជឿន ៖ ចុះបើរត់ ម៉េចក៏មិនយកសាក់ការដូទៅ យើងជឿថាមិនរត់ទេ ជឿថាយកទៅ គ្រាន់គេមិនឲ្យយើងដឹងថាគេយកទៅធ្វើម៉េច យើងអត់ដឹងគេ ។

ធានី ៖ ពូដឹងនៅទំនប់នឹង ពូដឹងថាគេជីកនឹងមានជម្រៅប៉ុន្មានម៉ែត្រ ហើយកំពស់ប៉ុន្មាន បណ្តោយប៉ុន្មាន ទទឹងប៉ុន្មាន?

ជឿន ៖ អូ! មិនអាចដឹងបានក្មួយអើយ អារឿងនឹង យើងមិនទៅឈរវាស់ ឈរថាដឹង ទាល់តែអ្នក ។

ធានី ៖ តែស្មាន ព្ទថាពូសុទ្ធតែរត់ឡើង?

ជឿន ៖ ១៥ម៉ែត្រដឹង តាមមើលដូចមិនតិចទេ ។

ធានី ៖ ចុះបាតវា?

ជឿន ៖ បាតវាធំណាស់ បាតវាចូល៥០ មិនផុតពី៥០ ធំណាស់ដើមទំនប់ៗត្រពាំងថ្ម បាតធំណាស់ ។

ធានី ៖ ឥឡូវអត់ដឹង?

ជឿន ៖ អូ! ខ្ញុំអត់ដែលទៅ តាំងពីចប់រឿងថ្ងៃណា ខ្ញុំមិនដែលទៅជិតសោះបើទៅលេងទៅកន្លែងខ្ញុំអត់ដែលទៅទេ តែកូនចៅខ្ញុំថាកុំទៅកន្លែងអស់នឹង កន្លែងវិនាសកម្ម ។

ធានី ៖ ចិត្តពូគិតចឹង?

ជឿន ៖ ខ្ញុំគិតចឹង ខ្ញុំថាកន្លែងនឹងព្រោះខ្ញុំវាសោកសៅកន្លែងនឹង ដោយសារវាឆ្អែតឆ្អល់កន្លែងនឹងអាស៊ីអត់បាយម៉ោយប់វាស់ព្រឹកក៏ទៅនឹង អាដេកមិនបានក៏ទៅនឹង អាឈឺក៏កន្លែងនឹង បានថាឈប់ឲ្យឃើញត្រង់នឹង ។

ធានី ៖ ហេតុអីពូ?

ជឿន ៖ ដូចថានឹកឃើញថ្មីៗ ។

ធានី ៖ អត់ហ៊ានចង់ទៅប្រឈមមុខនឹង?

ជឿន ៖ បាទ! ប្រឈម វាមិនទៅខ្វាចអីទេ នឹកឃើញកុំឲ្យឃើញបំភ្លេចវាចោលសិន ថ្ងៃណាមួយចង់ឲ្យភ្លេចទៅបានទៅ ។

ធានី ៖ ថ្ងៃណាភ្លេច?

ជឿន ៖ ថ្ងៃណាភ្លេច ដល់យូរទៅយើងចាស់ជាងនឹងទៀត ថ្ងៃយើងកាន់សីល កាន់ធម៌ កាន់អាថ៌យើងរំសាយចិត្ត យើងឈប់ហើយអានឹង ជារឿងកម្មផល ជារឿងអីចឹងទៅ ដាក់ទៅចឹងវិញ ។

ធានី ៖ ចុះកាលនឹងពូថាប្អូនរបស់ពូ ជាមួយម្ដាយពូនៅឃុំទឹកជោរ ហើយពូមកចល័តនៅនេះ ម៉េចបានពូដឹងថាម្ដាយពូ និងប្អូនពូត្រូវស្លាប់អស់បាយ?

ជឿន ៖ នែក! អានឹងអ្នកស្គាល់គ្នា ដូចថាប្រជាជនអ្នកនៅជិតខាងតិចតួចគេប្រាប់ហើយថាគាត់ឈឺ អាវាគចេញឈាមហើយណា មួលចេញឈាមស្លាប់ដោយសារអានឹងឯង ។ ប្រហែលជា គាត់អត់អីហូប គាត់ចេះតែហូបប៉ះផ្លែឈើផ្លៃព្រៃចេះឃ្លាន ។

ធានី ៖ ពុល?

ជឿន ៖ បាទ! ហូបចឹងទៅ ឈឺ ។

ធានី ៖ ហើយស្គាល់ឈ្មោះអ្នកប្រាប់ពូ?

ជឿន ៖ អ្នកប្រាប់នឹងងាប់បាត់ហើយ ។

ធានី ៖ ឈ្មោះអីគេ?

ជឿន ៖ កូនក្មេងតូចៗ មិនដឹងជាប្រាប់ រកប្រាប់ឈ្មោះមិនបានដែរនឹង ខ្ញុំនិយាយប្រាប់ទៅបើខ្ញុំមិនលាក់ការណ៍អីគេត្រង់កន្លែងនឹង បើថាវាចល័តតូចៗនៅកុមារអីចឹង ។ ម៉ែមិត្តឯងងាប់បាត់ ហើយមួលចេញឈាមស្លាប់បាត់ហើយ ។ ដល់ពេលនេះថា ប្អូនមិត្តឯងគេយកទៅពេទ្យទឹកជោរបាត់ ។ ដល់នេះប្អូនខ្ញុំផ្ដាំខ្ញុំឲ្យទៅជួប ដល់សុំគេៗថាមិនឲ្យទៅទេ ។

ធានី ៖ សុំអ្នកណាគេ?

ជឿន ៖ កាលនោះសុំអង្គភាពគេៗឥឡូវទៅមើល ថាមិនបាច់ទៅមើលទេ ។

ធានី ៖ ឈ្មោះអីគេ?

ជឿន ៖ អង្គភាពនឹងពួកអានិរតីនឹងគេទៅបាត់ហើយនឹង អត់ចាំឈ្មោះគេទេ ។

ធានី ៖ តែដឹងថាខាងនិរតីមក?

ជឿន ៖ មកគេថាមិនបាច់គិតទេ ពេទ្យគេមើលហើយ ដល់ពេលក្រោយមកទៀតស្លាប់ ។ ដល់ស្លាប់នេះ ដឹងស្លាប់ដែលបែកគ្នា ជួបគ្នា ម្ដាយស្លាប់ ប្អូនស្លាប់ ។

ធានី ៖ អ្នកណាអ្នកប្រាប់?

ជឿន ៖ អានឹងអ្នកភូមិ អ្នកផង បើអ្នកមកពីនោះដូចគ្នា អាប្អូនខ្ញុំអាប្រុសមួយវាចូលមុនថាម្ដាយស្លាប់ហើយ ដែលបងស្លាប់ហើយ ។ ម្ដាយស្លាប់កាលខ្ញុំទៅលើទំនប់នៅទួលស្នាច់ ។

ធានី ៖ ឆ្នាំប៉ុន្មាន ឆ្នាំ៧៧?

ជឿន ៖ បាទ! លើកទំនប់ស្នាច់នឹង ។

ធានី ៖ ប្អូនស្រីនឹងឆ្នាំ៧៧ដែរ?

ជឿន ៖ ៧៧ វាខុសគ្នាទៅវាឈឺទាំង២នាក់ គ្រាន់ម៉ែម្ដាយស្លាប់មុន ។

ធានី ៖ មុនប្រហែលប៉ុន្មានខែ?

ជឿន ៖ ប្រហែល៥-៦ខែប៉ុននោះអត់យូរទេ ។

ធានី ៖ ចង់សួរចិត្តពូមកដល់សព្វថ្ងៃនេះ តើពូយល់យ៉ាងម៉េចដែរ ដូចថាការរំលឹករឿងរ៉ាវសម្រាប់ក្មេងក្រោយៗ ក៏ដូចជាអ្វីដែលពូបានប្រាប់មិញថា មិនចង់ទៅឃើញទេ ត្រពាំងថ្មនឹង ប៉ុន្តែពូអត់បានត្រឡប់ទៅស្រុកវិញទេ សុខចិត្តមករស់នៅក្នុងស្រុកព្រះនេត្រព្រះនឹង?

ជឿន ៖ អារឿងដែលខ្ញុំមិនត្រឡប់ទៅស្រុកវិញ អានឹងខ្ញុំនិយាយឲ្យចំថាមិនជាម៉េចទេ អត់មានទំនាស់អីជាមួយស្រុកនោះទេ គ្រាន់ខ្ញុំមានមុខការនៅនេះទៅ ខ្ញុំរកនៅនេះទៅដូចថាជីវភាពខ្ញុំ អាចចេះរីកដុះដាលទៅ ខ្ញុំចេះតែនៅ បងប្អូនកូនខ្ញុំចេះថា

បើថាអត់មានការងារ ទៅភ្នំពេញ វិញ ។ រកការងារធ្វើទៅ បម្រើការងាររដ្ឋទៅណា ។ ដល់នេះមិនបាច់ទេ ព្រោះខ្ញុំមានការ ងារនេះហើយ ចេះតែធ្វើទៅ ។

ធានី : កាលពូមកធ្វើការនៅនេះដំបូងធ្វើការអី?

ជឿន : ខ្ញុំគ្មានធ្វើអី ខ្ញុំគ្រាន់តែធ្វើស្រែ ធ្វើចំការ តែគ្រាន់ថារកស៊ីចេះតែបាន ចេះតែកើនបានដូច ថាវាមានចំណូល ។

ធានី : ចេះសប្បាយចិត្ត?

ជឿន : បាទ! មិនមែនថា ហ៎!គៀកព្រំដែនរករត់អីទេ អត់មែនទេ អត់មានគំនិតចឹង ថាមានប៉ុននេះរស់ហើយ ។

ធានី : ចង់សួរចិត្តពូដូចថាធម្មតាស្រុកនឹង ជាស្រុកដែលម្ដាយពូ ក៏ដូចចាប្អូនពូ ហើយនឹងពូធ្វើការងារបាក់កម្លាំងអីចឹង វាមានអារម្មណ៍ដកនៅក្នុងចិត្តថាស្រុកនឹងជាស្រុកដែលយើងមានរឿងរ៉ាវជាច្រើនដែលបានឆ្លងកាត់ ហើយមានការឈឺចាប់អីចឹង តើចិត្តពូ ធ្វើយ៉ាងម៉េចបានអាចរសាយនូវការគិតនឹង ទោះជាស្រុកនឹងមែនប៉ុន្តែវាមើលទៅដូចជានៅឆ្ងាយ?

ជឿន : នេះ! អារឿងត្រង់នេះ ដូចខ្ញុំនិយាយយើងគិតធម៌អាថ៌ខ្លះទៅ ជារឿងកម្មផល ទម្លាក់វាចឹងវិញ ចប់រឿងកម្មផល អត់មានអីពិបាកទេ ។ ទុកជាយើងខំសោកសៅយ៉ាងណា ទុកយើងឈឺចាប់យ៉ាងណា ក៏វាមិនអាចវិលត្រឡប់មករកយើងវិញ ។

ធានី : ចឹងពូធ្វើម៉េច?

ជឿន : ត្រូវរៀន យើងគិតថាជារឿងកម្មផល ដូចខ្ញុំនិយាយចឹង អានឹងជាកម្មរបស់យើងចុះដែល គេរស់ ចុះគេមិនអី ជារឿងអីជាកម្មផលដែរ ។

ធានី : ពូគិតរឿងកម្មផលព្រះពុទ្ធសាសនា?

ជឿន : បាទ! ខ្ញុំគិតទៅតាមនឹងវិញ បើមិនគិតទៅតាមនឹងវិញ កំហឹងចេះតែមានបើមិនចឹងចេះតែ បើមិនចឹងទេ ចេះតែខឹងអានេះចេះធ្វើអញ អញធ្វើឯង ទាស់គ្នា ។ ហើយយើងឈប់យក ច្បាប់ យកសិទ្ធិអីមកនិយាយ វាត្រូវហួសសម័យដែលយើងត្រូវធ្វើចឹង ។ មិនបាច់សង សឹកអីទៀតទេ វាចប់រឿងអាអ្នកដែលសងសឹកវាងាប់តគ្នា ។

ធានី : ពូគិតចឹង?

ជឿន ៖ បាទ! ខ្ញុំយល់ឃើញចឹង បើយើងសាងអំពើល្អគឺបានល្អហើយ ឈប់កុំឲ្យមានតែធ្វើបុណ្យបញ្ជូនឲ្យទៅ ។ ខ្ញុំក៏ធ្វើបុណ្យធ្វើទានបញ្ជូនទៅឲ្យឪពុកម្ដាយខ្ញុំទាំងអស់គ្នានឹងបងប្អូនប្រជាពល រដ្ឋ ។

ធានី ៖ ទោះជាអត់បានឃើញសាកសព?

ជឿន ៖ បាទ! អត់ឃើញក៏ដោយ ខ្ញុំធ្វើដើម្បីអានឹងដូចថាឧទ្ទិសទៅវិញ្ញាណក្ខ័ន្ធដែលគាត់បាត់បង់ជីវិត ។

ធានី ៖ ចឹងពូធ្វើបុណ្យនឹងធ្វើតែម្ដាយឪពុកពូទេ ឬក៏?

ជឿន ៖ ទាំងអស់រួមផ្សំ ។

ធានី ៖ ទាំងអ្នកណាខ្លះ?

ជឿន ៖ ទាំងប្អូនខ្ញុំដែលបាត់ទាំងអស់គ្នានឹង ។

ធានី ៖ ហើយអ្នកណាទៀត?

ជឿន ៖ ប្អូន២នាក់នឹង ម្ដាយខ្ញុំមួយឪពុកខ្ញុំទៀត ឪពុកខ្ញុំស្លាប់នៅជំនាន់នោះធ្វើបុណ្យស្រួលបួលតែនៅរំលឹកវិញ្ញាណក្ខ័ន្ធគាត់មកធ្វើបុណ្យបង្សុកូល រំលឹករាល់ឆ្នាំ ។ តែអារឿងដែលថាទីកន្លែងដែលធ្លាប់មានប៉ះទង្គិច ឈប់សូវគិតច្រើន បើថាយើងឈប់ឃើញឈប់គិត តែយើងទៅឃើញ វាចេះតែគិតថាអានឹងម៉ែអញចេះ ឪអញចោះ ។

ធានី ៖ ចឹងពូមានអីបន្ថែមទៀតអត់?

ជឿន ៖ អត់មានអីបន្ថែមទៀតទេ គ្រាន់ចង់និយាយរឿងនឹង ។

ធានី ៖ ពូមានលេខទូរស័ព្ទ?

ជឿន ៖ ០៥៤ ៦៤ ៩៥ ១៦៨ ។

ធានី ៖ អរគុណពូច្រើន ។

ជឿន ៖ បាទ!

«ចប់»